# សហគមន៍ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង

**KHMER KAMPUCHEA KROM COMMUNITY-NORTH AMERICA**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM- L'AMÉRIQUE DU NORD**


## លិខិតចូលរួមមរណទុក្ខ

**ប្រគេន និង ជូន**

**ព្រះតេជៈព្រះគុណ ថេរ៉ូ គិម តាំង ទទួលបន្ទុកសាសនកិច្ច**

**លោក ថាច់ ជា តំណាងគ្រួសារព្រះសព**

**លោកប្រធានសមាគមខ្មែរកម្ពុជាក្រោម-សហរដ្ឋអាមេរិក ថាច់ តាន់ តារា**

**លោក ចៅ សុខបាន តំណាងគណៈកម្មការវត្តកម្ពុជាក្រោម**

សហគមន៍ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង លោកប្រធានកិត្តិយស សឺន ហ. ហេនរី លោកប្រធានក្រុមប្រឹក្សាភិបាល ថាច់ ឃ្លាំង សហសេវិក សមាជិក សមាជិកា និងក្នុងនាមខ្ញុំព្រះករុណា ខ្ញុំបាទផ្ទាល់ មានសេចក្តីតក់ស្លុត និង សោកស្តាយជាពន់ពេក ដោយបានទទួលពតិមានដ៏សង្វេគយ៉ាងខ្លាំង ក្នុងការទទួលព្រះអនិច្ចធម្មរបស់ព្រះគ្រូចៅអធិការវត្តកម្ពុជាក្រោម **ព្រះភិក្ខុ សុវណ្ណបញ្ញោ ថាច់ សួន** នាថ្ងៃសៅរ៍ ០៤រោច ខែ បុស្ស ឆ្នាំកុរ នព្វស័ក ព.ស.២៥៥១ ត្រូវនឹងថ្ងៃទី ២៦ ខែ មករា គ.ស. ២០០៨ ដោយព្រះរោគាពាធ ក្នុងព្រះជន្ម ៨០វស្សា (២៨ មេសា ១៩២៨ - ២៦ មករា ២០០៨) ។

យើងខ្ញុំព្រះករុណា ខ្ញុំបាទ សហសេវិក សមាជិក និងសមាជិកាសហគមន៍ខ្មែរកម្ពុជាក្រោម នៅឯនាយសមុទ្រ សូមចូលរួមមរណទុក្ខជាមួយព្រះតេជៈព្រះគុណម្ចាស់គ្រប់ៗព្រះអង្គ និង លោកទាំងអស់ក្នុងគ្រាដ៏មហាលំបាកនេះ ។

យើងខ្ញុំព្រះករុណា ខ្ញុំបាទ សហសេវិក សមាជិក និងសមាជិកាសហគមន៍ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង សូមគោរពព្រះវិញ្ញាណក្ខ័ន្ធព្រះវីរសមណៈ សុវណ្ណបញ្ញោ ថាច់ សួន នូវព្រះវិរភាព និងព្រះបូជនីយកិច្ចដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ ដើម្បីជាតិខេមរា ព្រះពុទ្ធសាសនា អត្តសញ្ញាណខ្មែរ ភាសាសាស្ត្រ អក្សរសាស្ត្រ អរិយធមិ វប្បធមិ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ។ ការសុគតរបស់ព្រះតេជៈព្រះគុណម្ចាស់ សុវណ្ណបញ្ញោ ថាច់ សួន គឺជាការបាត់បង់ព្រះវិរសមណៈដ៏ឆ្នើមមួយព្រះអង្គ នៅក្នុងសហ-គមន៍ខ្មែរទាំងមូល ។

សូមព្រះវិញ្ញាណក្ខ័ន្ធព្រះអង្គ សុវណ្ណបញ្ញោ ថាច់ សួន និមន្តទៅសោយសុខក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

ទីក្រុងឡូវែល សហរដ្ឋអាមេរិក ថ្ងៃទី២៨ ខែ មករា គ.ស.២០០៨

**គិម ប.ម. សគល**

នាយកប្រតិបត្តិ

---


Website: www.khmerkromngo.org
Mailing address in the United States & Canada: P.O. Box 1836, Lowell, MA 01853 U.S.A.
E-mail: KKCpressoffice@yahoo.com